# ឯកឧត្តម ចម ប្រសិទ្ធ ជួបប្រតិភូក្រុមហ៊ុនផលិតស្រោមដៃ TOP GLOVE SND.BHD នៃប្រទេសម៉ាឡេស៊ី




នៅរសៀលថ្ងៃ ១៥ ខែ កក្កដា ឆ្នាំ២០១០ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ពាណិជ្ជកម្ម បានអនុញ្ញាតឱ្យប្រតិភូក្រុមហ៊ុនផលិតស្រោមដៃ **TOP GLOVE SDN.BHD** នៃប្រទេស ម៉ាឡេស៊ី ដឹកនាំដោយលោក **Tan Sri Dato Sri Lim Wee Chai** ជាប្រធានក្រុមហ៊ុន និងសហការី ចូលជួបពិភាក្សាការងារ នៅទីស្តីការក្រសួង ។

លោក **Tan Sri Dato Sri Lim Wee Chai** ប្រធានក្រុមហ៊ុនផលិតស្រោមដៃ **TOP GLOVE SDN.BHD** នៃប្រទេសម៉ាឡេស៊ី បានជំរាបជូនពីគោលបំណងនៃជំនួបពិភាក្សា គឺដើម្បីសិក្សាស្វែងយល់ពីឱកាសវិនិយោគ ផ្នែកដាំដំណាំកៅស៊ូ-រោងចក្រកែច្នៃជ័រកៅស៊ូ និងពិនិត្យលទ្ធភាពការបង្កើតរោងចក្រផលិតស្រោមដៃជាតិកៅស៊ូ នៅកម្ពុជា ។

ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានសំដែងនូវការស្វាគមន៍ និងជំរាបជូនពីសក្តានុពល និងលក្ខណៈអំណោយផលរបស់កម្ពុជា ដែលជាប្រទេសកសិកម្ម សម្បូរណ៍ដោយធនធានធម្មជាតិ និងសម្បត្តិវប្បធម៌រុងរឿង។ ពិសេសកម្ពុជាទទួលបានសុខសន្តិភាពទូទាំងប្រទេស មានស្ថេរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ដែលជាឱកាសដ៏ប្រសើរសំរាប់វិនិយោគិនគ្រប់ជាតិសាសន៍ ក្នុងការបណ្តាក់ទុនវិនិយោគនៅកម្ពុជា ។ ទាក់ទងនិងគ្រោងការវិនិយោគរបស់ក្រុមហ៊ុនម៉ាឡេស៊ីខាងលើ ផ្នែកដំណាំកៅស៊ូ ឯកឧត្តមទេសរដ្ឋមន្ត្រី បានសំដែងនូវការស្វាគមន៍ ពីព្រោះក្រុមហ៊ុនមកពីប្រទេសម៉ាឡេស៊ីមានបទពិសោធន៍ខ្ពស់លើវិស័យនេះ ។ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានផ្តល់សារៈសំខាន់និងអត្ថប្រយោជន៍ទៅលើការបង្កើតរោងចក្រកែច្នៃជ័រកៅស៊ូ និងរោងចក្រផលិតស្រោមដៃនៅកម្ពុជា ដែលមានឥទ្ធិពលជាវិជ្ជមានទៅដល់ទីផ្សារការងារ ទទួលបានតំលៃបន្ថែម និងលើកកំពស់ការិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ឯកឧត្តមទេសរដ្ឋមន្ត្រីបានបញ្ជាក់បន្ថែមថា: ការផលិតដើម្បីនាំចេញ ដោយប្រើប្រភពដើមទំនិញពីកម្ពុជា ក្រុមហ៊ុនទាំង ឡាយ នឹងទទួលបានអត្ថប្រយោជន៍ជាអតិបរមា ពីព្រោះប្រទេសកម្ពុជា ជាប្រទេសអភិវឌ្ឍន៍តិចតួច ដែល ទទួលភាពអនុគ្រោះពាណិជ្ជកម្ម ពីប្រទេសអភិវឌ្ឍន៍

និងប្រទេសដៃគូជាច្រើន ដែលអនុញ្ញាតឱ្យទំនិញពីកម្ពុជា រាប់ពាន់មុខ អាចនាំចេញដោយមិនជាប់ពន្ធ និងមិនជាប់កូតា ដូចជាៈទីផ្សារសហគមន៍អឺរ៉ុប-សហរដ្ឋអាមេរិក-កាណាដា-អូស្ត្រាលី-ចិន-ជប៉ុន-ឥណ្ឌ និងប្រេស៊ីល ជាដើម ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានអំពាវនាវឱ្យអ្នកវិនិយោគនៃ ប្រទេសម៉ាឡេស៊ីមកបណ្តាក់ទុននៅកម្ពុជាឱ្យបានច្រើនថែមទៀត ជាពិសេសទៅលើវិស័យកសិកម្ម-កសិ ឧស្សាហកម្ម-សេវាកម្ម និង ទេស- ចរណ៍ ។ល។